ទស្សនៈ អ្នកនិពន្ធ

វ៉ុល៣, លេខ១៣, ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១

# ភាពជាដៃគូសន្តិសុខត្រីភាគី AUKUS និងភាពចាំបាច់សម្រាប់ឯកភាពអាស៊ាន

បណ្ឌិត អ៊ុន ឃាង *

កាលពីដើមខែកញ្ញាកន្លងទៅ សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងអូស្ត្រាលី បានធ្វើឱ្យប្រទេសជាច្រើនភ្ញាក់ផ្អើលជាមួយនឹងការប្រកាសបង្កើតភាពជាដៃគូសន្តិសុខត្រីភាគី ដែលត្រូវបានគេហៅថាអកកឹស (AUKUS)។ កិច្ចព្រមព្រៀងមួយនេះសំដៅលើការផ្ទេរបច្ចេកវិទ្យានានា ក្នុងចំណោមនោះរួមមានបច្ចេកវិទ្យាយោធាទំនើបចុងក្រោយសហរដ្ឋអាមេរិក ជាក់ស្តែង គឺនាវាមុជទឹកបំពាក់ដោយថាមពលនុយក្លេអ៊ែរឱ្យប្រទេសអូស្ត្រាលី តាមរយៈការផលិតជាជំហានដំបូងនូវនាវាមុជទឹកបំពាក់ដោយថាមពលនុយក្លេអ៊ែរចំនួន៨ គ្រឿង។ ការប្រកាសអំពីការបង្កើតកិច្ចព្រមព្រៀងសន្តិសុខត្រីភាគីអកគឹសនេះ គឺជាការបង្ហាញពីភូមិសាស្ត្រជាយុទ្ធសាស្ត្រថ្មីរបស់សហរដ្ឋអាមេរិកដើម្បីទប់ទល់នឹងចិន បើទោះបីមិនមានការប្រកាសជាផ្លូវការថានេះជាយុទ្ធសាស្ត្រនេះក៏ដោយ។

ក្នុងរយៈពេលជាងបួនទសវត្សរ៍ចុងក្រោយនេះ ចិនទទួលបានការលូតលាស់សេដ្ឋកិច្ចយ៉ាងខ្លាំង ដែលមិនធ្លាប់មានពីមុនមក ដែលអនុញ្ញាតឱ្យចិនចាប់ផ្តើមមានឥទ្ធិពល លើប្រព័ន្ធអន្តរជាតិក្រោយសង្គ្រាមត្រជាក់ ដែលត្រូវបានដឹកនាំដោយសហរដ្ឋអាមេរិក ហើយដែលចិន និងប្រទេសតតិយលោកជាច្រើនយល់ថា ជាប្រព័ន្ធមជ្ឈបស្ចិមលោកបង្កើតឡើងក្រោមបាវចនា *«អ្វីៗដែលល្អសម្រាប់បស្ចិមលោក គឺល្អសម្រាប់ពិភពលោកទាំងមូល»* ដោយមិនគិតគូរដល់ពហុភាពនៃប្រវត្តិសាស្ត្រ វប្បធម៌ និងកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្នុងទសវត្សរ៍ទីមួយនៃសតវត្សរ៍ទី២១នេះ ចិន បានចាប់ផ្តើមផ្តល់គំរូអភិវឌ្ឍន៍មួយដែលជំនួស ឱ្យប្រព័ន្ធអន្តរជាតិពិភពលោកដែលដឹកនាំដោយសហរដ្ឋអាមេរិក។ គំនិតផ្តួចផ្តើមផ្លូវមួយខ្សែក្រវាត់មួយ (BRI) របស់ចិន គឺជាគម្រោងមួយនៅក្នុងចំណោមគម្រោងអភិវឌ្ឍន៍ដ៏លេចធ្លោបំផុត នៅលើឆាកសេដ្ឋកិច្ចនយោបាយអន្តរជាតិក្នុងសតវត្សរ៍នេះ ដែលផ្តោតលើកម្មវិធីសាកលនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងពាណិជ្ជកម្ម ហើយដែលមានវិសាលភាពគ្របដណ្តប់លើពហុទ្វីប។ វាគឺជាគម្រោងដ៏សំខាន់បំផុតនៃគំរូអភិវឌ្ឍន៍ថ្មីរបស់ចិន។ ចិនបាន និងកំពុងប្រើប្រាស់អំណាចសេដ្ឋកិច្ចរបស់ខ្លួនដើម្បីស្តារមុខមាត់របស់ខ្លួនឡើងវិញនៅលើឆាក អន្តរជាតិដែលកន្លងមកត្រូវបានញាំញីដោយបស្ចិមប្រទេស ដែលចិនហៅថា «សតវត្សរ៍នៃភាពអាម៉ាស់ (Century of Humiliation)»។ ការទាមទារទឹកដីរបស់ចិនបានរួមបញ្ចូលទាំងដែនទឹកមួយផ្នែកយ៉ាងធំនៅសមុទ្រចិនខាងត្បូង ដែលចិនចាត់ទុកជាដែនទឹកដីប្រវត្តិសាស្ត្ររបស់ខ្លួន។

ការកើនឡើងនៃអំណាចរបស់ចិន និងការលើកកម្ពស់សេដ្ឋកិច្ចនយោបាយសកលថ្មីរបស់ខ្លួន បានធ្វើឱ្យសហរដ្ឋអាមេរិកមានការព្រួយបារម្ភយ៉ាងខ្លាំង។ ក្នុងការយល់ឃើញរបស់អាមេរិក ការត្រួតត្រារបស់ចិននៅក្នុងសមុទ្រចិនខាងត្បូង ប្រសិនបើមិនមានវិធានការទេ នឹងធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ និងផលប្រយោជន៍សេដ្ឋកិច្ចរបស់អាមេរិក និងសម្ព័ន្ធមិត្តរបស់ខ្លួននៅក្នុងតំបន់ និងអាចលើសពីនេះ។ គួរកត់សម្គាល់ផងដែរថា ក្រៅពីជាផ្លូវនាវាចរដ៏សំខាន់ សមុទ្រចិនខាងត្បូង គឺជាជង្រុក

* **បណ្ឌិត អ៊ុន ឃាង** គឺជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយ នៅសាកលវិទ្យាល័យ Northern Illinois សហរដ្ឋអាមេរិក និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

© *រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

ធនធានធម្មជាតិមានតម្លៃដ៏ច្រើនសន្ធឹកសន្ធាប់ ដូចជា ឧស្ម័នធម្មជាតិ ប្រេងកាត និងមច្ឆជាតិជាដើម។ នៅក្នុងក្រសែភ្នែករបស់សហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្ត ការត្រួតត្រារបស់ចិនលើសមុទ្រចិនខាងត្បូង នឹងអនុញ្ញាតឱ្យចិនអាចពង្រីក និងពង្រឹងអំណាចយោធា និងសេដ្ឋកិច្ចរបស់ខ្លួនកាន់តែខ្លាំងឡើងថែមទៀត។

ដើម្បីទប់ទល់នឹងឥទ្ធិពលរបស់ចិន ប៉ុន្មានឆ្នាំចុងក្រោយនេះ សហរដ្ឋអាមេរិកបានប្រឹងប្រែងពង្រឹងសម្ព័ន្ធភាពទ្វេភាគីរបស់ខ្លួនដែលមានស្រាប់ជាមួយប្រទេសជាច្រើន នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក និងបង្កើតសម្ព័ន្ធភាពពហុភាគីថ្មីៗនៅក្នុងតំបន់មានដូចជាកិច្ចសន្ទនាសន្តិសុខចតុភាគី ដែលមានសហរដ្ឋអាមេរិក អូស្ត្រាលី ជប៉ុន និងឥណ្ឌា ជាសមាជិក និងថ្មីៗនេះ គឺអកគឹស។ កិច្ចសន្ទនាសន្តិសុខចតុភាគីនេះ ប្រហែលជាមិនអាចបម្រើឱ្យទិសដៅយុទ្ធសាស្ត្ររបស់អាមេរិក ក្នុងការទប់ទល់នឹងអំណាចរបស់ចិន ឱ្យបានពេញលេញនោះទេ ដោយសារតែវាមានគោលបំណងទូលំទូលាយ និងដៃគូសហការច្រើន។ ហេតុដូចនេះ សហរដ្ឋអាមេរិកត្រូវការកិច្ចព្រមព្រៀងមួយដែលមានលក្ខណៈតូចតែខ្លឹម ដូចជា អកគឹស។ ដោយសារភាពតានតឹងក្នុងទំនាក់ទំនងរវាងចិន និងអូស្ត្រាលីនាពេលថ្មីៗនេះលើប្រភពនៃវីរុសកូរ៉ូណាថ្មី បញ្ហាពាណិជ្ជកម្ម និងសិទ្ធិមនុស្ស និងកត្តាទីតាំងភូមិសាស្ត្រជាយុទ្ធសាស្ត្ររបស់អូស្ត្រាលី ក៏ដូចជាទស្សនៈយល់ឃើញដូចគ្នាទៅលើពិភពលោករបស់សហរដ្ឋអាមេរិក និងអូស្ត្រាលី ជាលក្ខណៈធម្មជាតិ អូស្ត្រាលីគឺជាដៃគូរបស់សហរដ្ឋអាមេរិក ក្នុងការបង្កើតកិច្ចព្រមព្រៀង អកគឹស ដែលមានលក្ខណៈតូចតែខ្លឹមនេះ។

កិច្ចព្រមព្រៀងអកគឹសមានផលប៉ះពាល់ទូលំទូលាយសម្រាប់អាស៊ាន។ ទីមួយ ដោយគ្មានមន្ទិលសង្ស័យ កិច្ចព្រមព្រៀងអកគឹសនេះ អាចនឹងបង្កជាអស្ថិរភាពតំបន់នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ខណៈពេលដែលអូស្ត្រាលីយល់ឃើញថាអកគឹសគឺជាកិច្ចព្រមព្រៀងការពារខ្លួន ប្រទេសដទៃទៀត ជាក់ស្តែងរួមមានចិន និងឥណ្ឌូណេស៊ីជាដើម អាចនឹងចាត់ទុកកិច្ចព្រមព្រៀងអកគឹស ថាជាសម្ព័ន្ធភាពដែលមានលក្ខណៈ ឈ្លានពានប្រឆាំងនឹងប្រទេសខ្លួន។ ប្រវត្តិសាស្ត្រជារួមបានបង្ហាញដោយសោកនាដកម្មថា សកម្មភាពការពារខ្លួននៃប្រទេសមួយ អាចត្រូវបានប្រទេសផ្សេងទៀតចាត់ទុកថាជា ឥរិយាបថឈ្លានពានដែលជាលក្ខខណ្ឌអាចបង្កឱ្យមានការប្រណាំងប្រជែងសព្វាវុធ និងអាចឈានទៅដល់ការផ្ទុះជម្លោះប្រដាប់អាវុធជាដើម។ ហេតុដូច្នេះ អកគឹស ជះឥទ្ធិពលយ៉ាងខ្លាំងលើសន្តិសុខ និងស្ថិរភាពរបស់អាស៊ាន ជាពិសេស នៅពេលដែលទីតាំងភូមិសាស្ត្ររបស់អាស៊ានស្ថិតនៅចំចំណុចស្នូល នៃការប្រកួតប្រជែងរវាងចិន-អាមេរិក។

ទីពីរ គឺជាលទ្ធភាពនៃការថយចុះនៃសារៈសំខាន់របស់អាស៊ានក្នុងនាមជានិម្មាបនិកនៃសន្តិសុខតំបន់។ សេចក្តីថ្លែងការណ៍អកគឹសបានអះអាងសារឡើងវិញ អំពីការប្តេជ្ញាចិត្ត របស់សហរដ្ឋអាមេរិក និងអូស្ត្រាលីទៅលើ *«អាស៊ីអាគ្នេយ៍មជ្ឈភាពរបស់អាស៊ាន និងនិម្មាបនកម្មអាស៊ាន»*។[1] ជាក់ស្តែង ការសម្ងាត់ដែលឈានទៅដល់ការប្រកាសពីការបង្កើតសម្ព័ន្ធភាពអកគឹសនេះ បង្ហាញពីភាពផ្ទុយទៅវិញ។ ដើម្បីចៀសវាងពីការផាត់ចោលនៃអាស៊ាន វាទាមទារឱ្យប្រទេសជាសមាជិកអាស៊ានបង្ហាញពីការរួបរួម ក្នុងការដោះស្រាយ ជាមួយប្រទេសមហាអំណាចខាងក្រៅ។ ប្រតិកម្មដែលមានលក្ខណៈផ្សេងគ្នា និងបែកខ្ញែកគ្នាកន្លងទៅថ្មីៗនេះ ចំពោះកិច្ចព្រមព្រៀង អកគឹសមិនបង្ហាញពីផលល្អទេ ចំពោះការជំរុញឯកភាពរបស់អាស៊ាន។ ខណៈពេលដែលម៉ាឡេស៊ី និងឥណ្ឌូណេស៊ីបានបង្ហាញពីការមិនពេញចិត្ត ចំពោះអកគឹស សិង្ហបុរី និងហ្វីលីពីនបានបង្ហាញពីការគាំទ្រលើសម្ព័ន្ធភាពមួយ

[1] សូមមើល “The Australia-U.S. Ministerial Consultations Joint Statement: An Unbreakable Alliance for Peace and Prosperity,” <https://www.foreignminister.gov.au/minister/marise-payne/media-release/australia-us-ministerial-consultations-joint-statement-unbreakable-alliance-peace-and-prosperity.>

នេះ។ ថ្វីត្បិតតែ វៀត-ណាមរក្សាភាពស្ងៀមស្ងាត់ ដោយសារខ្លាចប៉ះពាល់ទំនាក់ទំនងជាមួយចំពោះចិន វៀតណាមបានស្វាគមន៍កិច្ចព្រមព្រៀងនេះដោយស្ងាត់ស្ងៀម។

សំណួរចុងក្រោយនោះគឺថា តើអ្វីទៅដែលត្រូវធ្វើ? អាស៊ានគួរតែមានកិច្ចសន្ទនារួមគ្នាដោយឥតលាក់លៀមទៅលើផលវិបាកនានាដែលកើតចេញពីការកើនឡើងនៃឥទ្ធិពលរបស់ចិន និងតួនាទីរបស់ចិនក្នុងសន្តិភាពតំបន់ និងការអភិវឌ្ឍសេដ្ឋកិច្ចតំបន់។ អាស៊ានគួរបង្ហាញពីជំហររួម ដែលកើតចេញពីកិច្ចសន្ទនារបស់ខ្លួនឱ្យចិនបានយល់។ វាមិនមានផលល្អ ហើយអាចនឹងមានគ្រោះថ្នាក់សម្រាប់សមាជិកអាស៊ានណាមួយ ដែលគាំទ្រការយល់ឃើញរបស់អាមេរិក និងគំនិតរបស់សម្ព័ន្ធមិត្តទៅលើចិន ថាជាតួអង្គដែលប្រកបដោយការគំរាមកំហែង និងមិនមានភាពទទួលខុសត្រូវ។ ទោះបីយ៉ាងណាក៏ដោយ ចិនមិនដូចអតីតសហភាពសូវៀតនោះទេ។ ចាប់តាំងពីការធ្វើកំណែទម្រង់របស់ខ្លួននៅចុងទស្សវត្សរ៍១៩៧០ ចិនមិនដែលទម្លាក់វាំងននដែក ដើម្បីផ្តាច់ខ្លួនពីពិភពលោកនោះទេ។ ក្នុងនាមជាប្រទេសមហាអំណាច ចិនមិនចង់ឱ្យគេមើលឃើញថាខ្លួនជាអ្នកសម្លុតគំរាមកំហែងគេ ហើយក៏មិនអត់ឱនដល់អ្នកដទៃដែលសម្លុតគំរាមកំហែងខ្លួននោះដែរ។ ហេតុដូច្នេះ ការដើរតាមទស្សនៈអាមេរិក និងសម្ព័ន្ធមិត្តរបស់អាមេរិកទៅលើចិន ដោយមិនបានពិចារណា នឹងប្រថុយប្រថានដែលអាចធ្វើឱ្យអាស៊ានក្លាយជា «រឿងក្រៅឆាក» នៃការប៉ុនប៉ងរបស់អាមេរិកក្នុងការខ្ទប់ឥទ្ធិពលចិន។

ក្នុងការវិភាគចុងក្រោយ អាស៊ានគួរតែបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនទ្វេដងដើម្បីសម្រេចនិយាមសកម្មភាព នៅសមុទ្រចិនខាងត្បូងដោយឈរលើគោលការណ៍ឈ្នះ-ឈ្នះ។ ក្នុងនាមជាប្រទេសមួយដែលមានទំនាក់ទំនងជិតស្និទ្ធ ជាមួយចិន ហើយមិនមានជម្លោះដែនទឹកនៅក្នុងសមុទ្រចិនខាងត្បូង កម្ពុជាគួរតែប្រើតួនាទីរបស់ខ្លួនក្នុងនាមជាប្រធានអាស៊ាន នៅឆ្នាំ២០២២ ដើម្បីសម្រេចឱ្យបាននូវនិយាមសកម្មភាពដែលមានលក្ខណៈឈ្នះ-ឈ្នះ នៅលើបញ្ហាសមុទ្រចិនខាងត្បូង។ ការធានាឱ្យបានលទ្ធផលបែបនេះ ពិតជានឹងក្លាយជាមូលដ្ឋាននៃការកសាងទំនុកចិត្តមួយ ដែលអាចត្រួសត្រាយផ្លូវសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក ដែលប្រកបកិច្ចសហការ វិបុលភាព និងសន្តិភាព។

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center (t.me/cdcenterkh)
Building E, University of Puthisastra, #55, Street 180-184, Sangkat Boeung Raing, Khan Daun Penh
info@cd-center.org | (+855) 10 950 456 www.cd-center.org
មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center